**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងអភិវឌ្ឍន៍ជនបទ**

លេខ: ១៣៦/១៤ ក.អ.ជ.ប្រក

ថ្ងៃអង្គារ ៥រោច ខែជេស្ឋ ឆ្នាំមមី ព.ស.២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែមិថុនា គ.ស.២០១៤

# ប្រកាស
## ស្តីពី
## ការកែសម្រួលមន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

## រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី ២១ ខែមិថុនា ឆ្នាំ ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ០១ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- យោងសារាចរណែនាំលេខ ១២ សរណន ចុះថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០១៣ របស់រាជរដ្ឋាភិបាល ស្តីពីការតែងតាំងមន្ត្រីខុទ្ទកាល័យ និងជំនួយការថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់
- យោងតម្រូវការចាំបាច់របស់ក្រសួងអភិវឌ្ឍន៍ជនបទ



អាសយដ្ឋាន កាច់ជ្រុងផ្លូវលេខ 169 និងមហាវិថីសហព័ន្ធរុស្ស៊ី រាជធានីភ្នំពេញ ទូរស័ព្ទ (855) 23 724 193
ទូរសារ (855) 23 881 615 ប្រអប់សំបុត្រ 2016 គេហទំព័រ www.mrd.gov.kh អ៊ីមែល mrd.cabinet@gmail.com

## សម្រេច

**ប្រការ ១.** កែសម្រួលសមាសភាពមន្ត្រីខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ដែលមានរាយនាមដូចខាងក្រោម÷

| | | |
|---|---|---|
| ១. | **ឯកឧត្តមបណ្ឌិត ថេង ចំន្ទសទ្វារ** | នាយកខុទ្ទកាល័យ |
| ២. | **លោក ផារ៉ា មង្គល** | នាយខុទ្ទកាល័យ |
| ៣. | **លោក ឡេង គីឈំង** | សមាជិកខុទ្ទកាល័យ |
| ៤. | **លោក ហេង ម៉ុនធឿន** | សមាជិកខុទ្ទកាល័យ |
| ៥. | **កញ្ញា នូសុវត្ថិ ចាន់វត្តី** | សមាជិកខុទ្ទកាល័យ |

**ប្រការ ២.** មន្ត្រីខុទ្ទកាល័យមានភារកិច្ចដូចមានចែងក្នុងជំពូកទី ៦ នៃអនុក្រឹត្យលេខ ២០ អនក្រ. បក ចុះថ្ងៃទី ៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

**ប្រការ ៣.** សេចក្ដីសម្រេចទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤.** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរ អង្គភាពទាំងអស់ក្រោមឱវាទក្រសួងអភិវឌ្ឍន៍ជនបទ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ជា សុផារ៉ា**

<u>ចម្លងជូន</u>

-ទីស្ដីការគណៈរដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័ន

-ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី

" <u>ដើម្បីជូនជ្រាប</u> "

-ដូចប្រការ ៤

"<u>ដើម្បីអនុវត្ត</u>"

-ឯកសារ -កាលប្បវត្តិ